Khmer
[DOH-8440]

*ប័ណ្ណព័ត៌មានអំពីជំងឺឆ្លង*

# ជំងឺគ្រុនលឿង

*ជំងឺគ្រុនលឿងគឺជារោគបង្កដោយវីរុសដែលមានលទ្ធភាពធ្វើឲ្យបាត់បង់ជីវិត ហើយដែលចម្លងដោយសត្វមូសនៅក្នុងតំបន់ទាំងឡាយនៃអាមេរិកខាងត្បូងនិងទ្វីបអាហ្វ្រិក។ អ្នកធ្វើដំណើរទៅកាន់តំបន់ទាំងនេះ ត្រូវចាក់ថ្នាំបង្ការរោគនេះ។*

## តើជំងឺគ្រុនលឿងគឺជាអ្វី?

ជំងឺគ្រុនលឿងគឺជារោគបង្កដោយវីរុសដែលឆ្លងទៅមនុស្សដោយសារសត្វមូស នៅក្នុងតំបន់ទាំងឡាយនៃអាមេរិកខាងត្បូងនិងទ្វីបអាហ្វ្រិក។

## តើជំងឺនេះមានរោគសញ្ញាអ្វីខ្លះ?

- រោគសញ្ញាទាំងឡាយនៃការឆ្លងរោគនេះមានរួមទាំងគ្រុនក្តៅមួយរំពេច រងាញ័រខ្លួន ឈឺសាច់ដុំ ឈឺចង្កេះ ឈឺក្បាល ចង្អោរ និងក្អួត នៅពេលបីទៅប្រាំមួយថ្ងៃក្រោយពីវីរុសនេះចូលទៅក្នុងរាងកាយ។ ក្រោយពេលបីទៅបួនថ្ងៃមក អ្នកជំងឺភាគច្រើនមានភាពគ្រាន់បើខ្លះ ហើយរោគសញ្ញាបានបាត់ទៅវិញ។
- ប៉ុន្តែអ្នកជំងឺប្រហែល 15% នឹងមានរោគសញ្ញាតទៅទៀតដោយមានការចេញឈាម (ចេញពីមាត់ ច្រមុះ និងភ្នែក និង/ឬក្រពះ) ខាន់លឿង(ស្បែកនិងភ្នែកឡើងពណ៌លឿង) ឈឺពោះដោយមានការក្អួត ព្រមទាំងតំរងទឹកនោមមានបញ្ហាក្នុងការបំពេញមុខងារ។ ចំនួនពាក់កណ្តាលនៃអ្នកជំងឺទាំងនេះជាសះស្បើយមកវិញ ប៉ុន្តែចំនួនពាក់កណ្តាលទៀតស្លាប់បាត់បង់ជីវិតក្នុងរង្វង់ពេល 10-14 ថ្ងៃ ក្រោយពីកើតមានរោគសញ្ញាទាំងនេះ។

## តើជំងឺនេះឆ្លងតាមរបៀបណា?

- មនុស្សនិងសត្វស្វាគឺជាសត្វលោកចំបងគេដែលឆ្លងវីរុសនេះ
- ពពួកសត្វមូសជាក់លាក់ដែលស្គាល់ថាជាពពួកសត្វមូស Aedes aegypti ជាសត្វចម្លងវីរុសនេះ
- ជំងឺនេះត្រូវការពេលបីទៅប្រាំមួយថ្ងៃដើម្បីចាប់ផ្តើមកើតមានឡើង បន្ទាប់ពីសត្វមូសមានមេរោគនេះបានខាំអ្នកណាម្នាក់
- អ្នកជំងឺអាចចម្លងមេរោគនេះទៅកាន់សត្វមូសរហូតដល់ពេល 5 ថ្ងៃ ក្រោយពីកើតមានរោគសញ្ញាទាំងឡាយ
- ជំងឺនេះមិនឆ្លងដោយផ្ទាល់ពីមនុស្សទៅមនុស្ស ឬពីសត្វទៅមនុស្សឡើយ លើកលែងតែពពួកសត្វមូស Aedes aegypti ទៅមនុស្ស។

## តើអ្នកណាដែលអាចមានគ្រោះថ្នាក់កើតជំងឺនេះ?

ជំងឺគ្រុនលឿងកើតមានឡើងនៅទ្វីបអាហ្វ្រិកនិងអាមេរិកខាងត្បូង នៅក្នុងបណ្តាប្រទេសស្ថិតនៅជិតអេក្វាទ័រតែប៉ុណ្ណោះ។ អ្នកធ្វើដំណើរដែលមិនសាំនឹងរោគនេះ និងអ្នករស់នៅក្នុងតំបន់ទាំងនេះមានគ្រោះថ្នាក់កើតជំងឺនេះ។

## តើវិធីបង្ការជំងឺនេះធ្វើឡើងដោយរបៀបណា?

ការចាក់ថ្នាំបង្ការរោគគឺជាវិធីមានប្រសិទ្ធភាពបំផុតដើម្បីបង្ការជំងឺគ្រុនលឿង។

- ការចាក់ថ្នាំបង្ការរោគត្រូវធ្វើនៅឯមណ្ឌលចាក់ថ្នាំបង្ការរោគដែលមានការយល់ព្រម ហើយមណ្ឌលនោះត្រូវផ្តល់សំបុត្របញ្ជាក់អន្តរជាតិអំពីការចាក់ថ្នាំបង្ការរោគគ្រុនលឿង។ ផ្នែកសុខភាពសាធារណៈ (Public Health Unit) ក្នុងតំបន់លោកអ្នកអាចផ្តល់បញ្ជីនៃមណ្ឌលចាក់ថ្នាំបង្ការរោគដែលមានការយល់ព្រម (សូមអានព័ត៌មានដើម្បីទាក់ទងនៅខាងក្រោម)
- នៅក្រោម*ច្បាប់យកទៅទុកដោយឡែករបស់អូស្ត្រាលី 1908 (Australian Quarantine Act, 1908)* ជនរាល់រូបដែលមានអាយុច្រើនជាងមួយឆ្នាំ ត្រូវមានសំបុត្របញ្ជាក់អន្តរជាតិអំពីការចាក់ថ្នាំបង្ការរោគគ្រុនលឿង បើជននោះបានស្នាក់នៅមួយយប់ឬយូរជាងនេះនៅក្នុងប្រទេសណាមួយដែលមានការប្រកាសថាមានជំងឺគ្រុនលឿង ក្នុងរង្វង់ពេលប្រាំមួយថ្ងៃមុនពេលធ្វើដំណើរទៅដល់ប្រទេសអូស្ត្រាលី។ លោកអ្នកអាចរកឃើញបញ្ជីឈ្មោះបណ្តាប្រទេសដែលប្រកាសថាមានជំងឺគ្រុនលឿង នៅតាមវ៉ិបសៃ៖
  http://www.health.gov.au/internet/wcms/publishing.nsf/content/health-pubhlth-strateg-communic-factsheets-yellow.htm
- ប្រទេសទាំងឡាយអាចបដិសេធមិនឲ្យជនណាមួយចូលទៅក្នុងប្រទេសគេឡើយ បើជននោះគ្មានសំបុត្របញ្ជាក់ការចាក់ថ្នាំបង្ការរោគគ្រុនលឿងដែលយកជាការបាន ហើយដែលនៅពេលថ្មីៗនេះបានស្ថិតនៅក្នុងប្រទេសដែលកើតមានជំងឺគ្រុនលឿង។ ប្រទេសទាំងនេះខ្លះអាចអនុញ្ញាតឲ្យអ្នកដែលមិនបានចាក់ថ្នាំបង្ការរោគចូលបាន ក្រោយពីបានចាក់ថ្នាំបង្ការរោគនៅឯច្រកព្រំដែនរបស់ប្រទេសទាំងនោះ។ ថ្នាំបង្ការរោគដែលចាក់ឲ្យនៅក្នុងស្ថានការណ៍ដូចនោះ ប្រហែលជាមិនអាចធានានូវការរម្ងាប់មេរោគឡើយ។
- អ្នកទៅដល់ប្រទេសអូស្ត្រាលី ដែលចេញពីប្រទេសមានជំងឺគ្រុនលឿងដោយគ្មានសំបុត្របញ្ជាក់ការចាក់ថ្នាំបង្ការរោគគ្រុនលឿង នឹងទទួលការសម្ភាសន៍ពីសំណាក់មន្ត្រីមកពីសេវាអធិការកិច្ចអូស្ត្រាលីយកទៅទុកដោយឡែក (Australian Quarantine Inspection Service-AQIS) នៅពេលទៅដល់។ មន្ត្រី AQIS អាចអនុញ្ញាតឲ្យអ្នកមិនបានចាក់ថ្នាំបង្ការរោគចូលទៅក្នុងប្រទេសអូស្ត្រាលីបាន តែនៅក្នុងករណីដែលអ្នកនោះយល់ព្រមជាលាយលក្ខណ៍អក្សរក្នុងការរាយការណ៍ប្រាប់អាជ្ញាធរសុខាភិបាល បើខ្លួនកើតមានរោគសញ្ញាណាមួយនៃជំងឺគ្រុនលឿងនៅក្នុងពេលប្រាំមួយថ្ងៃ ក្រោយពីការចាកចេញរបស់ខ្លួនពីទីកន្លែងមួយដែលប្រកាសថាកើតមានជំងឺគ្រុនលឿង។

អ្នកធ្វើដំណើរទៅកាន់ប្រទេសកើតមានជំងឺគ្រុនលឿងក៏គួរចាប់យកវិធានការផងដែរ ដើម្បីកុំឲ្យសត្វមូសខាំ៖

- ស្លៀកពាក់ខោអាវរលុងដែលមានជើងវែងនិងដៃវែង
- លាបថ្នាំបង្ការសត្វមូសខាំ (មានជាតិ DEET ឬ picardin) លើកន្លែងទាំងឡាយនៃរាងកាយដែលមិនគ្របដណ្តប់ជិត
- ស្នាក់នៅក្នុងទីសំណាក់ដែលការពារទល់នឹងសត្វមូស (ឧទាហរណ៍៖ ចងមុងលើគ្រែដំណេក)។

## តើការវិនិច្ឆ័យរោគធ្វើទៅតាមរបៀបណា?

ការវិនិច្ឆ័យរោគគ្រុនលឿងមានការលំបាកនៅដំណាក់កាលដើមដំបូងរបស់ជំងឺនេះ ដោយសារតែជំងឺមួយចំនួនអាចមានសញ្ញានិងរោគសញ្ញាស្រដៀងគ្នាដែរ។ ការវិនិច្ឆ័យរោគតម្រូវឲ្យធ្វើតេស្តឈាម។

## តើវិធីព្យាបាលជំងឺនេះធ្វើឡើងដោយរបៀបណា?

- គ្មានការព្យាបាលជាក់លាក់សំរាប់ជំងឺគ្រុនលឿងទេ។ អ្នកជំងឺអាចទទួលការព្យាបាលចំពោះកង្វះជាតិទឹកក្នុងខ្លួននិងគ្រុនក្តៅ។ ការថែទាំល្អិតល្អន់អាចជាការចាំបាច់សំរាប់អ្នកជំងឺដែលមានភាពធ្ងន់ធ្ងរខ្លាំង
- នៅក្នុងតំបន់ទាំងឡាយដែលសត្វមូស *Aedes aegypti* រស់នៅ (ដូចជាគ្វីនស្លេនខាងជើងជាដើម) អ្នកជំងឺគួរទទួលការថែទាំនៅក្នុងបន្ទប់ដែលការពារមិនឲ្យមានសត្វមូស។

## តើផ្នែកសុខភាពសាធារណៈមានវិធានការឆ្លើយតបអ្វីខ្លះ?

មន្ទីរពិសោធន៍និងមន្ទីរពេទ្យត្រូវរាយការណ៍នូវករណីនៃជំងឺគ្រុនលឿងប្រាប់ផ្នែកសុខភាពសាធារណៈក្នុងតំបន់។ ផ្នែកនេះនឹងស៊ើបអង្កេតករណីនៃអ្នកដែលមានលទ្ធភាពកើតជំងឺនេះ ដើម្បីរកមើលឲ្យដឹងកត្តាគ្រោះថ្នាក់ទាំងឡាយដែលធ្វើឲ្យមានជំងឺនេះ និងបង្ការការឆ្លងទៅកាន់សត្វមូសនៅក្នុងបណ្ដាតំបន់ដែលអាចចម្លងជំងឺនេះនៅក្នុងប្រទេសអូស្ត្រាលី។

## ព័ត៌មានបន្ថែម – ផ្នែកសុខភាពសាធារណៈ (Public Health) នៅក្នុងរដ្ឋ NSW



**1300 066 055**

[www.health.nsw.gov.au](http://www.health.nsw.gov.au)